# ការធ្វើទ្រុងជ្រូក និងស្នូក

យើងអាចធ្វើទ្រុងជ្រូក និងស្នូកចំណី តាមបែបលក្ខណៈគ្រួសារ ឬបែបអាជីវកម្មក៏បាន អាស្រ័យតាមលទ្ធភាព និងធនធាន ។

## ការធ្វើទ្រុង

### សំភារៈ



# ដំណាក់នៃការធ្វើទ្រុង

## គួរដឹង

គួរធ្វើទ្រុងជ្រូកនៅលើដីទួលឲ្យឆ្ងាយពីផ្ទះ បន្តិច ដើម្បីកុំឲ្យធុំក្លិន ស្អុយ ហើយទ្រុងត្រូវមានពន្លឺ និង ខ្យល់ ចេញចូលគ្រប់គ្រាន់ ។

- លើកដីបំពេញកន្លែងធ្វើទ្រុង កំពស់៣០សង់ទីម៉ែត្រ ។ បុកបង្ហាប់ដីឲ្យស្មើ និងឲ្យមានជំរាល បន្តិច ។ រួចចាក់សាបកំរាស់ពី ៣ ទៅ ៤សម ។
- ដាំបង្គោលមេចំនួន ៤ ដើម ដែលមានកំពស់១.៨ម(ម៉ែត្រ) នៅតាមជ្រុងនិមួយៗ និងដាំ បង្គោលកន្លោង ២ដើម កំពស់ ២.៥ម ។







## ហេតុអ្វីត្រូវចាក់សាប ?

ងាយស្រួលក្នុងការសំអាតទ្រុង និងប្រមូលកាកសំណល់(លាមក និងទឹកនោម) សំរាប់ធ្វើជីដាក់ ដំណាំ ។

## គួរដឹង

ទ្រុងជ្រូកមានទំហំ ២,៥ម X ២ម អាចដាក់ជ្រូកសាច់បានចំនួន៤ក្បាល ។

- ដាំបង្គោលកំពស់ ១ម នៅចន្លោះបង្គោលមេ ដើម្បីងាយស្រួលវាយរបាជុំវិញ និងឲ្យមាន ភាពរឹងមាំ ។ រៀបចំគ្រឿងដំបូលបំពាក់ពីលើបង្គោល សំរាប់ប្រក់ដំបូល ។
- វាយរបាជុំវិញទ្រុង ដោយទុកចន្លោះប្រហែល ១៥សម ចំពោះរបាទី១ ដល់ទី៣ ផ្នែក ខាងក្រោម ហើយចំពោះរបាបន្ទាប់មកខាងលើ ត្រូវទុកចន្លោះ ២០ សម ។







## ហេតុអ្វីត្រូវវាយរបាញឹកនៅផ្នែកខាងក្រោម ?

ដើម្បីកុំឲ្យជ្រូកតូចៗចេញពីទ្រុងបាន ។

## ជៀសវាង

- មិនត្រូវធ្វើដំបូលពីស័ង្កសីទេ ព្រោះវាស្រូបកំដៅខ្លាំង និង មានតម្លៃថ្លៃ។
- មិនត្រូវដាក់ជ្រូក ចិញ្ចឹមភ្លាម បន្ទាប់ពីធ្វើទ្រុងហើយនោះទេ ព្រោះស៊ីម៉ង់ត៍ធ្វើឲ្យស្បែកជ្រូកកើតរមាស់ ។

ដូច្នេះបន្ទាប់ពីធ្វើទ្រុងហើយ ត្រូវឧស្សាហ៍ស្រោចទឹកឲ្យបានញឹកញាប់ ក្នុងរយៈពេល ១ អាទិត្យ ដើម្បីឲ្យអស់ជាតិស៊ីម៉ង់ត៍ ។

- ទ្រុងជ្រូកចាំបាច់ត្រូវមានដំបូងត្រឹមត្រូវ ។ យើងអាចប្រើកូនឈើតូចៗ ឬឫស្សីសំរាប់ធ្វើគ្រឿងដំបូលក៏បានដោយប្រក់ស្លឹកត្នោត ឬស្បូវ ។
- មុននឹងដាក់ជ្រូកចិញ្ចឹម ត្រូវលាងសំអាត និងបាចកំបោរក្នុងទ្រុងដើម្បីសម្លាប់មេរោគ រួចទុកចោល ១អាទិត្យ ទើបលាងកំបោរនោះចេញ ។






## ហេតុអ្វីត្រូវធ្វើស្នូកចំណីពីស៊ីម៉ងត៍ ?

ដើម្បីជៀងវាងការដួលកំពប់ចំណី នៅពេលជ្រូកឡើងជាន់ស្នូក ឬពេលពួកវាដណ្ដើមគ្នាស៊ីចំណី ។

## ការធ្វើស្នូកចំណី




គួរធ្វើស្នូកចំណីស៊ីម៉ងត៍ ដោយចាក់ភ្ជាប់ទៅនឹងកំរាលតែម្ដង ដែលមានទទឹង ២០សម បណ្ដោយពី ៣០សម ទៅ ៣៥សម និង ជំរៅ ១៥សម ។



## ការធ្វើស្នូកទឹក

ធ្វើស្នូកទឹកដែលមានទទឹង និងបណ្ដោយប្រវែង ២០សម ។
ចំពោះស្នូកទឹក គួរចាក់ស៊ីម៉ងត៍ភ្ជាប់ក្បែរស្នូកចំណី ដើម្បីងាយស្រួលដាក់ទឹក និងចំណីផ្សេងពីគ្នា ។
ចំពោះស្នូកទឹក គេអាចប្រើធុងទឹក ដែលមានតក្បាលបឺតក៏បាន ។

១- ដាក់ធុងទឹកនៅលើរបាដែលខ្ពស់ជាងគេ រួចយកខ្សែចងធុងនោះឲ្យជាប់ ។

២- តទុយោចេញពីធុងទឹក រួចតភ្ជាប់ចុងទុយោម្ខាង ទៀតជាមួយក្បាលបឺត ។

៣- ចងទំលាក់ក្បាលបឺតភ្ជាប់ទៅនឹងផ្នែកណាមួយនៃទ្រុង ដើម្បីឲ្យជ្រូក ងាយស្រួលផឹកទឹក ។










### គួរដឹង



- គេអាចយកសំបកកង់ឡានចាស់ទៅពុះជា២ ឬចានដែក ឬ ធុងចាស់ ឬស្នូកឈើ មកប្រើជាស្នូកចំណី និងស្នូកទឹក ក៏បាន។
- ប៉ុន្តែបើមានលទ្ធភាពគួរប្រើធុងទឹកដែលមានក្បាលបឺតជួយ

សន្សំសំចៃទឹក ទ្រុងមិនសើម ចំណោញកន្លែង និងជ្រូកអាចផឹកទឹកពេលណាក៏បាន ។ យើងអាចរកទិញក្បាលបឺត នៅតាម ហាងលក់ចំណីសត្វ ។

(ដកស្រង់ចេញពីទស្សនាវដ្តីកសិករ របស់អង្គការសេដាក)